ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

*The Bar Association of the Kingdom of Cambodia*


# របាយការណ៍បញ្ចប់កម្មសិក្សា

**កម្មសិក្សាការី** ៖

**គ្រូកម្មសិក្សា** ៖

**ការិយាល័យមេធាវី** ៖

**អាសយដ្ឋាន** ៖

កាលបរិច្ឆេទចាប់ផ្ដើមកម្មសិក្សា ថ្ងៃទី ខែ ឆ្នាំ

កាលបរិច្ឆេទបញ្ចប់កម្មសិក្សា ថ្ងៃទី ខែ ឆ្នាំ

# មាតិកា

ទំព័រ

**អារម្ភកថា**.................................................................................................

**ផ្នែកទី ១. សេចក្តីផ្តើម**.................................................................................................

**១.១ សេចក្តីថ្លែងអំណរគុណ**.................................................................................

**១.២ លិខិតស្នើសុំបញ្ចប់កម្មសិក្សា**.......................................................................

**១.៣ លិខិតបញ្ជាក់របស់គ្រូកម្មសិក្សា**...........................................................

**ផ្នែកទី ២. តួសេចក្តី (របាយការណ៍សង្ខេប)** ..........................................................................

**២.១ សកម្មភាពទូទៅ**.........................................................................................

- ការចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល
- សសេរអត្ថបទ
- ផ្សេងៗ

**២.២ សកម្មភាពការពារក្តី (យ៉ាងហោចណាស់ ៦ក្តី: ព្រហ្មទណ្ឌ៣ រដ្ឋប្បវេណី ៣)**

២.២.១ រឿងក្តីព្រហ្មទណ្ឌ(សង្ខេបកិច្ចការដែលបានធ្វើក្នុងរឿងក្តីនីមួយៗ)

តារាងសង្ខេបរឿងក្តី

| ល.រ | ឈ្មោះកូនក្តី | ភេទ | អាយុ | លេខសំណុំរឿង | បទចោទ | សាលាជម្រះក្តី | ស្ថានភាពក្តី |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |

២.២.២ រឿងក្តីរដ្ឋប្បវេណី (សង្ខេបកិច្ចការដែលបានធ្វើក្នុងរឿងក្តីនីមួយៗ)

តារាងសង្ខេបរឿងក្តី

| ល.រ | ឈ្មោះកូនក្តី | ភេទ | អាយុ | លេខសំណុំរឿង | កម្មវត្ថុនៃបណ្តឹង | សាលាជម្រះក្តី | ស្ថានភាពក្តី |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | | | | | | | |

២.២.៣ ពិគ្រោះយោបល់ច្បាប់ ០៥ រឿង

| ល.រ | ឈ្មោះអតិថិជន | ភេទ | អាយុ | បញ្ហា/វិវាទ | លទ្ធផល |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |

**២.៣ ការបង្ហាញសមត្ថភាពការពាររឿងក្ដី**

២.៣.១ រឿងក្ដីព្រហ្មទណ្ឌដែលបានបញ្ចប់ជាស្ថាពរ ០១ រឿង

- សង្ខេបអង្គហេតុ
- ចំណុចខ្សោយ
- ចំណុចខ្លាំង
- សំណួរសម្រាប់សាក្សីរបស់មេធាវី
- សំណួរសម្រាប់សាក្សីរបស់ព្រះរាជអាជ្ញា
- ទ្រឹស្ដីការពារក្ដី
- សេចក្ដីសន្និដ្ឋានការពារ
- លទ្ធផលនៃការការពារក្ដី (សាលក្រម)

២.៣.២ រឿងក្ដីរដ្ឋប្បវេណីដែលបានបញ្ចប់ជាស្ថាពរ ០១ រឿង

- សង្ខេបអង្គហេតុ
- ចំណុចខ្សោយ
- ចំណុចខ្លាំង
- សំណួរសម្រាប់សាក្សីរបស់ខ្លួន

- សំណួរសម្រាប់សាក្សីរបស់ភាគីម្ខាងទៀត
- ទ្រឹស្តីការពារក្តី
- សេចក្តីសន្និដ្ឋានការពារ(សេចក្តីថ្លែងការណ៍)
- លទ្ធផលនៃការការពារក្តី (សាលក្រម)

**ផ្នែកទី ៣. សេចក្តីបញ្ចប់**

**១.ចំណាប់អារម្មណ៍ និង បញ្ហាប្រឈម**

**២. សំណូមពររបស់មេធាវីកម្មសិក្សា**

**ផ្នែកទី ៤. ឯកសារយោង**

៤.១ សេចក្តីសម្រេចអនុញ្ញាតអោយចូលប្រកបវិជ្ជាជីវៈមេធាវីលេខ ចុះថ្ងៃទី ខែ ឆ្នាំ

៤.២ កំណត់ហេតុសច្ចាប្រណិធានលេខ....ចុះថ្ងៃទី....ខែ....ឆ្នាំ....

៤.៣ ពាក្យសុំធ្វើកម្មសិក្សាចុះថ្ងៃទី.... ខែ....ឆ្នាំ.....

៤.៤ សេចក្តីសម្រេចអនុញ្ញាតឲ្យធ្វើកម្មសិក្សាលេខ...ចុះថ្ងៃទី...ខែ....ឆ្នាំ...

៤.៥ កិច្ចសហការរវាងគ្រូកម្មសិក្សា និងកម្មសិក្សាការី ចុះថ្ងៃទី....ខែ....ឆ្នាំ....

៤.៦ រឿងក្តីដែលបានបញ្ចប់

# ព្រាង

## អារម្ភកថា

ខ្ញុំបាទ/នាងខ្ញុំ..................................ត្រូវបានសមាជិកក្រុមប្រឹក្សាគណៈមេធាវីសម្រេចឲ្យធ្វើកម្មសិក្សារយៈពេល១២(ដប់ពីរ)ខែជាមួយគ្រូកម្មសិក្សាឈ្មោះ..............................និងនៅការិយាល័យមេធាវី............ដែលមានទីតាំងស្ថិតនៅ..........................................................................................។

ជាកាតព្វកិច្ចរបស់កម្មសិក្សាការីគ្រប់រូប នៅពេលបញ្ចប់កម្មសិក្សារយៈពេល ១២ ខែ រួចមក កម្មសិក្សាការីនីមួយៗត្រូវរៀបចំរបាយការណ៍បញ្ចប់កម្មសិក្សារបស់ខ្លួន ដោយត្រូវរៀបរាប់អំពីការធ្វើកម្មសិក្សាកន្លងមក រួមទាំងលទ្ធផលការងារដែលសម្រេចបាននៅក្នុងរយៈពេលកម្មសិក្សាកន្លងនោះ ដើម្បីធ្វើជាមូលដ្ឋានដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេចអំពីសមត្ថភាពក្នុងកម្មសិក្សារបស់កម្មសិក្សាការី ដែលនឹងឈានទៅជាមេធាវីពេញសិទ្ធិដ៏ឆាប់ខាងមុខនេះ ។

សៀវភៅរបាយការណ៍បញ្ចប់កម្មសិក្សានេះបញ្ជាក់អំពីសកម្មភាពការងារដែលកម្មសិក្សាការីបានបំពេញកន្លងមកដោយមានការចូលរួមពីសំណាក់គ្រូកម្មសិក្សាផងដែរ ។

ចំពោះទម្រង់របាយការបញ្ចប់កម្មសិក្សា ជាជំនួយស្មារតីសម្រាប់កម្មសិក្សាការី និងកម្មសិក្សាការីក៏បានផ្ទៀងផ្ទាត់ឡើងវិញផងដែរ ។

ថ្ងៃ.................ខែ........ឆ្នាំ................

............ថ្ងៃទី.......ខែ......ឆ្នាំ............

**កម្មសិក្សាការី**

# ព្រាង

**ការិយាល័យ/ក្រុមហ៊ុនមេធាវី**...........(Logo)

**សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទ/នាងខ្ញុំ សូមគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកឪពុក អ្នកម្តាយ និងអ្នកមានគុណ ដែល បង្កើតរូបខ្ញុំបាទ/នាងខ្ញុំ ចិញ្ចឹមបីបាច់ ថែរក្សា ទូន្មានប្រៀនប្រដៅ និងជួយទំនុកបំរុង ខ្ញុំបាទ/នាងខ្ញុំ ទទួលបាននូវលទ្ធផលនាពេលនេះ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះគ្រូកម្មសិក្សាមេធាវី ដែលបានទទួលយកខ្ញុំបាទ/នាងខ្ញុំធ្វើជាកម្មសិក្សាការី រយៈពេល កម្មសិក្សានេះ។ គ្រូកម្មសិក្សាមេធាវី តែងតែណែនាំ បង្ហាត់បង្រៀន ចែករំលែកបទពិសោធន៍ល្អៗដល់ខ្ញុំបាទ/នាងខ្ញុំ និងជួយដោះស្រាយរាល់បញ្ហាដែលកើតមាន និងផ្តល់អនុសាសន៍ពេលកម្មសិក្សា និងមុនបញ្ចប់កម្មសិក្សា ។

សូមថ្លែងអំណរគុណចំពោះប្រធានការិយាល័យ/ក្រុមហ៊ុនមេធាវី និងបុគ្គលិកបំរើការងារទាំងអស់ ដែលបានផ្តល់ការចែករំលែកបទពិសោធន៍ និងជួយការងាររូបខ្ញុំបាទ/នាងខ្ញុំ រយៈពេល ១២ ខែ កន្លងមក ។

សូមថ្លែងអំណរគុណចំពោះគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ឱកាសឲ្យខ្ញុំបាទ/នាងខ្ញុំ បានក្លាយជាសមាជិកគណៈមេធាវី ដើម្បីឲ្យខ្ញុំបាទ/នាងខ្ញុំអាចប្រើប្រាស់ចំណេះដឹងខាងវិស័យច្បាប់ ចូលរួមបម្រើយុត្តិធម៌សង្គម និងកសាងសង្គមជានីតិរដ្ឋ ។

ជាទីបញ្ចប់ ខ្ញុំបាទ/នាងខ្ញុំ សូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងអស់ក្នុងលោក ជួយថែរក្សាអ្នកមានគុណ គ្រូកម្មសិក្សា ព្រមទាំងលោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងបុគ្គលិកគណៈមេធាវីទាំងអស់ ឲ្យជួបប្រទះតែពុទ្ធពរគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ ។

ពី: ខ្ញុំបាទ/នាងខ្ញុំ....................។

**ព្រាង**

**វិយាល័យ/ក្រុមហ៊ុនមេធាវី**...........(Logo)

**លិខិតសុំបញ្ជូនរបាយការណ៍បញ្ចប់កម្មសិក្សា**

ខ្ញុំបាទ/នាងខ្ញុំ.........................ជាមេធាវីនៃការិយាល័យ/ក្រុមហ៊ុនមេធាវី.............អាសយដ្ឋានស្ថិតនៅទីតាំង.......................................................................................................................។

**សូមគោរពជូន**

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**តាមរយៈ** គ្រូកម្មសិក្សា........................

**កម្មវត្ថុ** ការបញ្ជូនរបាយការណ៍កម្មសិក្សា។

**យោង** ច្បាប់លក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ក្រមសីលធម៌មេធាវីគណៈមេធាវី

បទបញ្ជាផ្ទៃក្នុងគណៈមេធាវី

សេចក្តីសម្រេចរបស់គណៈមេធាវី........................

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ មានកត្តិយសសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំត្រូវបានសមាជិកក្រុមប្រឹក្សាគណៈមេធាវីសម្រេចឱ្យធ្វើកម្មសិក្សារយៈពេល ១២ (ដប់ពីរ)ខែជាមួយគ្រូកម្មសិក្សា......................នៅការិយាល័យ/ក្រុមហ៊ុនមេធាវី.................. ចាប់ពីថ្ងៃទី...ខែ...ឆ្នាំ...រហូតដល់ ថ្ងៃទី...ខែ...ឆ្នាំ...។ បន្ទាប់ពីបានធ្វើកម្មសិក្សារយៈពេល ១២ (ដប់ពីរ)ខែកន្លងមក ខ្ញុំបាទ/នាងខ្ញុំ សូម ស្នើសុំបញ្ជូនរបាយការណ៍បញ្ចប់កម្មសិក្សា ដើម្បីបង្ហាញអំពីសកម្មភាពការងារ និងការអនុវត្តជាក់ស្តែង និងដាក់ជូនគណៈមេធាវីមេត្តាពិនិត្យ និងសម្រេចចំពោះការបញ្ចប់កម្មសិក្សារបស់ខ្ញុំបាទ/នាងខ្ញុំ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ.................ខែ........ឆ្នាំ................

............ថ្ងៃទី.......ខែ......ឆ្នាំ............

**កម្មសិក្សាការី**

**ការិយាល័យ/ក្រុមហ៊ុនមេធាវី**...........(Logo)

**លិខិតសុំបញ្ជូនរបាយការណ៍បញ្ចប់កម្មសិក្សា**

ខ្ញុំបាទ/នាងខ្ញុំ.........................ជាមេធាវីនៃការិយាល័យ/ក្រុមហ៊ុនមេធាវី.............អាសយដ្ឋានស្ថិតនៅទីតាំង...........................................................................................................។

**សូមគោរពជូន**

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** ការបញ្ជូនរបាយការណ៍បញ្ចប់កម្មសិក្សារបស់កម្មសិក្សាការី...........................។

**យោង:** ច្បាប់លក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ក្រមសីលធម៌មេធាវីគណៈមេធាវី

បទបញ្ជាផ្ទៃក្នុងគណៈមេធាវី

សេចក្តីសម្រេចរបស់គណៈមេធាវី........................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ មានកត្តិយសសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា កម្មសិក្សាការី...........................ដែលបានធ្វើកម្មសិក្សាជាមួយខ្ញុំ នៅការិយាល័យ/ក្រុមហ៊ុនមេធាវី......................រយៈពេល ១២ (ដប់ពីរ)ខែចាប់ពីថ្ងៃទី...ខែ...ឆ្នាំ...រហូតដល់ ថ្ងៃទី...ខែ...ឆ្នាំ...កម្មសិក្សាការី បានបំពេញការងារ ទាំងចំណេះដឹង បទពិសោធន៍ និងបច្ចេកទេសសំខាន់ៗក្នុងការបំពេញការងារជា មេធាវីដូចជា៖

.......................................................................................................................................

.......................................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមបញ្ជូនរបាយការណ៍បញ្ចប់កម្មសិក្សារបស់កម្មសិក្សាការី...... ជូន **លោកប្រធាន** និងសមាជិកក្រុមប្រឹក្សាគណៈមេធាវីមេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ.................ខែ........ឆ្នាំ................

............ថ្ងៃទី.......ខែ......ឆ្នាំ............

**គ្រូកម្មសិក្សា**